CAMERA Spotlight

ត្រីមាសទី៣ ឆ្នាំ២០១៧
លេខចេញផ្សាយ #០៦

ព្រឹត្តិប័ត្រព័ត៌មាននៃបេសកកម្មសេវនដេយអាត់វេនទីស្នកម្ពុជា

បេសកកម្មសេវនដេយអាត់វេនទីស្នកម្ពុជា: ផ្ទះលេខ ១៥ ផ្លូវលេខ ៥៦៨ សង្កាត់បឹងកក់២ ខណ្ឌទួលគោក រាជធានីភ្នំពេញ
ទូរសព្ទ័លេខ: ០២៣ ៨៨៣ ៨៦៤ អីម៉ែល: sda@cam.adventist.asia គេហទំព័រ www.camadventist.org

ការប្រមូលផលជាពេលនៃអំណរនៅផែនដី និងនៅឋានសួគ៌

ព្រះគម្ពីរម៉ាថាយ ២៨:១៩-២០ "ដូច្នេះ ចូរទៅបញ្ចុះបញ្ចូលឲ្យមានសិស្សនៅគ្រប់ទាំងសាសន៍ ព្រមទាំងធ្វើបុណ្យជ្រមុជទឹកឲ្យដោយនូវព្រះនាមព្រះវរបិតា ព្រះរាជបុត្រា នឹងព្រះវិញ្ញាណបរិសុទ្ធចុះ ហើយបង្រៀនឲ្យគេកាន់តាមគ្រប់ទាំងសេចក្ដីដែលខ្ញុំបានបង្គាប់មកអ្នករាល់ គ្នាផង ហើយមើល ខ្ញុំក៏នៅជាមួយនឹងអ្នករាល់គ្នាជារាល់ថ្ងៃដែរ ដរាបដល់បំផុតកល្ប។ អាម៉ែន ។

នេះគឺជាទំនួលខុសត្រូវរបស់មនុស្សគ្រប់គ្នា។ បន្ទាប់ពីសកម្មភាពនៃការចុះសួរសុខទុក្ខ និងការបង្រៀនព្រះគម្ពីរ ព្រះវិហាររួមទាំងក្រុមថ្វាយបង្គំមួយចំនួនបានរៀបចំធ្វើកម្មវិធីផ្សាយដំណឹងល្អ ដើម្បីប្រមូលផលថ្វាយព្រះជាម្ចាស់ ក៏ដូចជាសាបព្រោះគ្រាប់ពូជនៃសេចក្ដីសង្ឃឹម និងសេចក្ដីសង្គ្រោះថ្មីៗបន្តទៀតផងដែរ។

រហូតមកត្រឹមចុងត្រីមាសទី៣ នៃឆ្នាំ២០១៧នេះ យ៉ាងហោចណាស់ក៏មានកម្មវិធីផ្សាយដំណឹងល្អចំនួន៦ ដែលបានរៀបចំឡើងដោយព្រះវិហារ និងក្រុមថ្វាយបង្គំនៅតាមកន្លែងផ្សេងៗគ្នារួមមាន៖ ខេត្តកំពង់ធំ ខេត្តពោធិ៍សាត់ ខេត្តកំពត ខេត្តក្រចេះ ខេត្តព្រៃវែង និងព្រះវិហារទួលគោកភ្នំពេញ។ ជាលទ្ធផលពីកម្មវិធីផ្សាយដំណឹងល្អទាំងនេះ មានសមាជិកថ្មីបានទទួលពិធីបុណ្យជ្រមុជទឹកចំនួន៥៩នាក់ ព្រមទាំងមានបងប្អូនមួយចំនួនផ្សេងទៀតមានចំណាប់អារម្មណ៍ក្នុងការសិក្សាព្រះគម្ពីរ។

ក្នុងចំណោមការផ្សាយដំណឹងល្អទាំងនេះ ព្រះវិហារទួលគោកបានទទួលការគាំទ្រពីលោក Tjak Latumahina ជនជាតិឥណ្ឌូនេស៊ី ក្នុងការចែកចាយព្រះបន្ទូលក៏ដូចជាផ្នែកថវិកាផងដែរសម្រាប់កម្មវិធីទាំងមូល។ កម្មវិធីនោះមានអ្នកចូលរួមប្រមាណពី២០០ទៅ៣០០នាក់រៀងរាល់យប់ ក្នុងនោះមានសមាជិករបស់ព្រះវិហារផ្ទាល់ និងអ្នកដែលមិនមែនជាសមាជិកនៅឡើយ។

១៣នាក់បានសំរេចចិត្តទទួលពិធីបុណ្យជ្រមុជទឹកនៅថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៧ បន្ទាប់ពីបានសិក្សាព្រះគម្ពីរជាមួយប៉ាស្ទ័រនឹងអ្នកបំរើកិច្ចការរបស់ព្រះវិហារ។ ជាការលើកទឹកចិត្ត ព្រះវិហារបានផ្តល់ជូននូវសញ្ញាប័ត្រ ក៏ដូចជាសំភារៈសិក្សាមួយចំនួនបន្ថែមទៀតក្នុងគោលបំណងជួយឲ្យសមាជិកថ្មីកាន់តែរីកចំរើនក្នុងការដើរជាមួយនិងព្រះជាម្ចាស់។

នៅចុងបញ្ចប់នៃកម្មវិធីផ្សាយដំណឹងល្អនេះ មានមនុស្សមួយចំនួនបានឆ្លើយតបទៅនិងការអំពាវនាវរបស់អ្នកចែកចាយព្រះបន្ទូល ពួកគេបានក្រោកឈរព្រមទាំងដើរទៅខាងមុខពួកជំនុំទាំងមូល។ សូមសរសើរដំកើងដល់ព្រះជាម្ចាស់ក្នុងការប៉ះពាល់ដល់ចិត្តអ្នកទាំងអស់គ្នានោះតាមរយៈព្រះបន្ទូលដែលចែកចាយដោយវាគ្មិនរបស់យើង។ ពីព្រះវិហារ យើងបានរៀបចំគំរោងដើម្បីបង្រៀនព្រះគម្ពីរថែមទៀតដល់អ្នកដែលចាប់អារម្មណ៍ចង់សិក្សាស្វែងយល់បន្ថែមទៀតពីព្រះយេស៊ូវ។

កម្មវិធីមេរៀនថ្ងៃសុក្រ

ប្រសិនបើលោកអ្នកមានទូរសព្ទ័ដែលដំណើរការដោយ (Android) លោកអ្នកអាចទាញយកតាមរយៈ:

Awrcambodia

camadventist.org

សិក្ខាសាលាសមាជិកសកម្ម

ជាថ្មីម្តងទៀតមជ្ឈមណ្ឌលហ្វឹកហ្វឺនបានពេញទៅដោយអ្នកចូលរួមប្រមាណជា៤៣អ្នកមកពីខេត្តនានាទូទាំងប្រទេសកម្ពុជា នេះជាសិក្ខាសាលាសមាជិកសកម្មដែលបានរៀបចំឡើងរយៈពេលពីរថ្ងៃចាប់ពីថ្ងៃទី២៦ដល់២៧ ខែសីហា ឆ្នាំ២០១៧ដោយបេសកកម្មសេវនដេយអាត់វេនទីស្នកម្ពុជា។

សិក្ខាសាលានេះមានគោលបំណងឡើងទឹកចិត្តដល់សមាជិកក្រុមជំនុំឲ្យចូលរួមពង្រឹងសេចក្តីជំនឿផ្ទាល់ខ្លួនក៏ដូចជាអ្នកជំទៃជាសមាជិករបស់ខ្លួនផងដែរ។ ពួកគេនឹងក្លាយទៅជាបុគ្គលយ៉ាងសំខាន់ក្នុងការលើកទឹកចិត្តដល់អ្នកជំទៃទៀតឲ្យមានសកម្មភាពខាងសេចក្តីជំនឿក៏ដូចជាចូលរួមផ្សាយដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទដល់អ្នកជំទៃ។ នេះក៏ជាយុទ្ធសាស្ត្រមួយស្របទៅតាមទិសដៅរបស់ព្រះវិហារផងដែរ គឺការចូលរួមពីគ្រប់សមាជិកដើម្បីជួយឲ្យព្រះវិហាររីកលូតលាស់។

សិក្ខាកាមមានការសំកីសិក្សាស្វែងយល់ជាខ្លាំងពីមេរៀនដែលបានចែកចាយពីសំណាក់មន្ត្រីមិសិន។ ពួកគេថែមទាំងបានស្នើឲ្យមានសិក្ខាសាលាបែបនេះទៀតយ៉ាងហោចណាស់ពីរលើកក្នុងមួយឆ្នាំ ប្រយោជន៍ឲ្យបានសិក្សាបន្ថែមអំពីរបៀបដែលពួកគេអាចជួយឲ្យពួកគេផ្ទាល់ក្លាយទៅជាសមាជិកដ៏មាំនិងរួមចំណែកជួយឲ្យសមាជិកព្រះវិហារជំទៃទៀតមានជំនឿមាំដែរ។ ការរួមសហការគ្នានោះយើងអាចបង្ហើយកិច្ចការដែលព្រះជាម្ចាស់បានបង្គាប់មក។ រួចហើយយើងអាចស្រែកយ៉ាងមានអំណរនៅថ្ងៃដែលព្រះទ្រង់នឹងយាងមកវិញនៅពេលឆាប់ៗខាងមុខនេះ។

កម្មវិធីផ្សាយដំណឹងល្អខេត្តបាត់ដំបង (៤-៥ ខែតុលា ឆ្នាំ២០១៧)

ព្រះបានប្រទានព្រះពរយ៉ាងច្រើនដល់ប្រទេសកម្ពុជា បើទោះបីជារដូវភ្លៀងឆ្នាំនេះមានការពិបាកក្នុងការធ្វើដំណើរតាមផ្លូវមួយចំនួនក្នុងខេត្តបាត់ដំបង ព្រមទាំងមានកន្លែងមួយចំនួនទៀតទទួលរងនូវទឹកជំនន់ក៏ដោយ។ ប៉ុន្តែ ព្រះមានអំណាចលើអ្វីៗគ្រប់យ៉ាងរួមទាំងអាកាសធាតុផងដែរ។ ទ្រង់បានឆ្លើយតបទៅនឹងសេចក្តីអធិស្ឋានរបស់យើង ពោលគឺភ្លៀងបានឈប់។ ព្រះបានបញ្ឈៀសភ្លៀងនៅពេលដែលយើងមានកម្មវិធីជួបជុំផ្សាយដំណឹងល្អ។ ដូច្នេះហើយទើបបានមានមនុស្សជាច្រើនអាចបានមកចូលរួមនិងស្តាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់នៅក្នុងឱកាសនោះ។

កិច្ចការទាំងឡាយក្នុងការរៀបចំកម្មវិធីផ្សាយដំណឹងល្អមួយនេះ គឺបានចាប់ផ្តើមតាំងពីមួយឆ្នាំមុនមកម្លេះ។ អ្នកបំរើទ្រង់បានចុះធ្វើកិច្ចការពីផ្ទះមួយទៅផ្ទះមួយទៀតក្នុងការអញ្ជើញបងប្អូនឲ្យសិក្សាព្រះគម្ពីរ។ ពួកគេបានដឹកនាំយ៉ាងសកម្មដល់ក្រុមតូចក៏ដូចជាបុគ្គលផ្ទាល់ខ្លួនម្នាក់ៗឲ្យសំកីសិក្សាព្រះគម្ពីរ។ ខណៈថ្ងៃនៃពិធីផ្សាយដំណឹងល្អបានឈានចូលមកដល់ ពួកយើងបានរៀបចំជារោង កៅអី និងអំពូលភ្លើង។ ផ្ទាំងពិដាយ៉ាងស្រស់ស្អាតបានលើកឡើងដែលនិយាយទាក់ទងទៅនិងប្រធានបទដែលលោកប៉ាស្ទ័រ Francis Amer នឹងចែកចាយ។ រីឯនាយកដ្ឋានយុវជននៃបេសកកម្មអាត់វេនទីស្នកម្ពុជាវិញក៏បានចូលរួមជួយជ្រោមជ្រែងផងដែរ ដោយបានប្រមូលយុវជនស្ម័គ្រចិត្តពីខេត្តឧត្តរមានជ័យ ពោធិ៍សាត់ និងពីខេត្តសៀមរាបដើម្បីជួយដល់កម្មវិធីនេះ។ ពេលថ្ងៃនៃកម្មវិធីនេះបានមកដល់មានមនុស្សប្រមាណជាជាង២០០នាក់មកចូលរួម និងរង់ចាំស្តាប់ព្រះបន្ទូល។ ក្រុមជំនុំនៅជិតទីនោះបាននាំញាតិមិត្តរបស់ពួកគេមកចូលរួម ខ្លះទៀតក៏បាននាំសិស្សានុសិស្សរបស់ពួកគេមកដែរ។ នៅពេលប៉ាស្ទ័រ Francis Amer ធ្វើការអំពាវនាវថា “តើមានអ្នកខ្លះចង់ដើរតាមព្រះយេស៊ូវ?”នោះមានមនុស្សជាច្រើនបានក្រោងឈរឡើង។ នៅថ្ងៃចុងបញ្ចប់នៃការផ្សាយដំណឹងល្អនេះមានមនុស្ស៣នាក់បានសំរេចចិត្តថ្វាយខ្លួនទៅព្រះតាមរយៈពិធីបុណ្យជ្រមុជទឹក។

នៅក្នុងបន្ទប់តូចមួយជិតបន្ទប់ផ្សាយដំណឹងល្អនោះ មានកុមារៗជាង១០០នាក់បានមកចូលរួមក្នុងកម្មវិធីផ្សាយដំណឹងល្អក្រោមប្រធានបទ “ពេលព្រះយេស៊ូវមានបន្ទូល នោះអ្វីៗក៏កើតមានឡើង” ។ ពួកគេមកដោយដើរ ខ្លះជិះកង់ និងមធ្យោបាយមួយចំនួនទៀត។ ជាការគួរឲ្យកត់សំគាល់ មានកម្មវិធីប្រណាំងទូកងនៅមិនឆ្ងាយពីទីតាំងនៃការផ្សាយដំណឹងល្អរបស់យើងនោះទេ ប៉ុន្តែ កុមារទាំងអស់នោះនៅតែសំរេចចិត្តមកចូលរួមកម្មវិធីផ្សាយដំណឹងល្អជាជាងទៅចូលរួមពិធីប្រណាំងទូកងនោះទៅវិញ។ សូមសរសើរដំកើងដល់ព្រះ! នៅចុងបញ្ចប់ពួកគេបានរៀនអំពីលោកសន្និវាសទាំងមូលស្តាប់បង្គាប់ទ្រង់ ហើយយើងក៏គួរតែស្តាប់បង្គាប់ទ្រង់ដែរ។

វិទ្យុសំឡេងមេត្រីភាព
សាមកនូវក្តីសង្ឃឹមសំរាប់ជីវិត

ផ្សាយតាមរលកធាតុអាកាសខ្លី (SW)
ព្រឹកម៉ោង៦ (SW=15.36KHz)
យប់ម៉ោង៨ (SW=11.90KHz)

097 80 81 060
awrcambodia
vol@awr.org
www.awr.org

វិទ្យុសំឡេងមេត្រីភាព

វិទ្យុសំឡេងមេត្រីភាពជាផ្នែកមួយនៃវិទ្យុអាត់វេនទីស្នពិភពលោក។ វាគឺជាព័ន្ធកិច្ចនៃវិទ្យុជាសកលរបស់ព្រះវិហារសេវេនដេយអាត់វេនទីស្ន។ ទិសដៅនៃវិទ្យុនេះគឺ ផ្សព្វផ្សាយពីសេចក្តីសង្ឃឹមនៅក្នុងព្រះគ្រីស្ទដល់អ្នកដែលរស់នៅកន្លែងដែលអ្នកផ្សាយដំណឹងពិបាកចូលទៅដល់ ដើម្បីឲ្យពួកគេបានឮព្រះបន្ទូលជាភាសារបស់ពួកគេផ្ទាល់។

តាមរយៈកម្មវិធីវិទ្យុសំឡេងមេត្រីភាព គឺមានមនុស្សជាច្រើនបានទទួលព្រះពរតាមរយៈសារនៃសេចក្តីសង្ឃឹម និងសេចក្តីសង្គ្រោះតាមរយៈវិទ្យុ ប្រព័ន្ធផ្សព្វផ្សាយសង្គម និងវិធីមួយចំនួនទៀត។ តាមរយៈការផ្សាយនេះ មានអ្នកស្តាប់ស្នើសុំនូវសំភារៈមួយចំនួនក្នុងការសិក្សាព្រះគម្ពីរបន្ថែមទៀត។ មានមនុស្សមួយចំនួនបានសំរេចចិត្តទទួលបុណ្យជ្រមុជទឹក និងបានក្លាយជាសមាជិកយ៉ាងសកម្មទៀតផង។

សំរាប់អ្នកស្តាប់មួយចំនួន ការស្តាប់វិទ្យុគឺជាវិធីតែមួយគត់ដែលអាចឮនូវសារនៃសេចក្តីសង្គ្រោះតាមរយៈព្រះយេស៊ូវគ្រីស្ទបាន។ សូមចូលរួមអធិស្ឋានឲ្យអ្នកស្តាប់ទាំងអស់មិនថាពេលយប់ឬពេលថ្ងៃទេ សូមឲ្យចិត្តពួកគេបានទទួលយកព្រះយេស៊ូវ។

លោកអ្នកអាចចូលរួមជាដៃគូរបស់យើងខ្ញុំបានតាមរយៈការចែកចាយដំណឹងពីវិទ្យុសំឡេងមេត្រីភាពដល់អ្នកដទៃ ផ្តាល់ជាវិទ្យុដល់គេ ឬក៏ជួយចែកចាយសំភារៈមួយចំនួនដូចជាសៀវភៅ ស៊ីឌី និងឧបករណ៍មួយចំនួនទៀតជាដើម។ល។

សិក្ខាសាលាគ្រូបង្រៀន

ថៃ្ងបំប៉ននៅថ្ងៃនេះ រៀនសូត្រសម្រាប់ថ្ងៃស្អែក រៀបចំចរិតលក្ខណៈសម្រាប់ភាពអស់កល្ប នេះគឺជាទិសដៅរបស់យើងចំពោះវិស័យអប់រំ។

ដើម្បីលើកកំពស់គុណភាពនៃសាលាជាពិសេសសាលាអាត់វេនទីស្នតូចៗទូទាំងប្រទេសកម្ពុជា នាយកដ្ឋានអប់រំនៅក្រោមការចង្អុលបង្ហាញពីបេសកកម្មសេវេនដេយអាត់វេនទីស្ន បានរៀបចំសិក្ខាសាលាដល់គ្រូៗរបស់យើងប្រចាំឆ្នាំ។

មុនពេលបើកបវេសនកាលឆ្នាំនេះ នាយកដ្ឋានអប់រំសហការជាមួយប្រធាននាយកដ្ឋានយុវជនបានរៀបចំសិក្ខាសាលាដល់គ្រូៗនៅតាមសាលានានានៅក្រោមប្រធានបទ “គ្រូដែលយកចិត្តទុកដាក់ យុទ្ធសាស្ត្រនៃការបង្រៀនដែលមានប្រសិទ្ធភាព និងយុទ្ធសាស្ត្រក្នុងការដោះស្រាយចំពោះសិស្សដែលមានឥរិយាបទមិនត្រឹមត្រូវ”។

សិក្ខាសាលានេះមានគ្រូៗចូលរួម៥៦នាក់មកពីសាលានានារួមបញ្ចូលអាយស៊ីស៊ីផងដែរ។

គោលបំណងដ៏ធំនៃសាលាអាត់វេនទីស្នគឺមិនមែនគ្រាន់តែរៀបចំសិស្សានុសិស្សទាំងអស់ឲ្យក្លាយទៅជាធនធានដ៏ល្អសំរាប់លោកិយនេះប៉ុណ្ណោះនោះទេ ប៉ុន្តែ ដើម្បីស្តារឡើងវិញនូវទំរង់ដែលបានបាត់បង់ដែលព្រះបានបង្កើតតាំងពីដើមកំណើតលោកិយមកម្ល៉េះ។

យើងចង់ឃើញគ្រូទាំងអស់ដើរតួដូចជាប៉ាស្ទ័រសម្រាប់សិស្សានុសិស្ស ព្រមទាំងបង្រៀនពីមេរៀននៃសេចក្តីជំនឿផងដែរ។ នាយកដ្ឋានអប់រំសូមថ្លែងអំណរគុណដល់មិសិនសំរាប់ការគាំទ្រទាំងស្រុងចំពោះវិស័យអប់រំ ហើយក៏សូមអរគុណចំពោះថ្នាក់ដឹកនាំនៃសាលានានាដែលបានបញ្ជូនគ្រូៗមកចូលរួមក្នុងសិក្ខាសាលានេះ។

ខ្ញុំដែលជាប្រធាននាយកដ្ឋានអប់រំ បានទទួលព្រះពរចំពោះឱកាសក្នុងការចែកចាយនូវបទពិសោធន៍ទាំងឡាយដល់សិក្ខាកាមទាំងអស់ដែលពួកគេហាក់បីដូចជាពន្លឺសម្រាប់សិស្សរបស់ខ្លួន។

ពិធីសម្ពោធដាក់ឲ្យប្រើប្រាស់អគារមណ្ឌលសុខភាព

ថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ គឺជាថ្ងៃដ៏សែនរំភើបរីករាយមួយសម្រាប់ប្រជាពលរដ្ឋដែលរស់នៅក្នុងឃុំគគីរធំ ស្រុកបារាយណ៍ ខេត្តកំពង់ធំ ដោយព្រោះថាមានអគារមណ្ឌលសុខភាព និងបន្ទប់រង់ចាំសម្រាលមួយខ្នងបានបង្ហាញខ្លួនឡើងបន្ទាប់ពីការសាងសង់ បានចប់រួចរាល់ជាស្ថាពរនិងបានសម្ពោធបើកដាក់ឲ្យប្រើប្រាស់ចាប់ពីពេលនេះតទៅ។

ក្នុងឱកាសពីធីសម្ពោធនេះអ្នកចូលរួមសរុបមាន៨៦៨ នាក់។ ក្នុងនោះរួមមាន ឯ.ឧ. សុខ លូ អភិបាលនៃគណៈអភិបាលខេត្តកំពង់ធំ លោក រ៉ាល់ វ៉ាត់ ២ ដែលជាអតីតនាយកអង្គការអាហ្វ្រាអន្តរជាតិរយៈពេល១៥ឆ្នាំ រួមជាមួយនឹងសហការី លោករ៉ាល់ វ៉ាត់៣ និងលោក ជេម ឡានីង ដែលពួកគាត់ទាំងអស់គ្នាជាតំណាងមកពីហែពអីនធីណេសិនណល ដែលជាម្ចាស់ ជំនួយថវិកានៃការសាងសង់មណ្ឌលសុខភាពនិងបន្ទប់រង់ចាំសម្រាលមួយនេះ និងមណ្ឌលសុខភាពពីរបន្ថែមទៀតដែលនឹងចាប់ផ្តើមដំណើរការសាងសង់ក្នុងពេលឆាប់ៗខាងមុខនេះ។ មានវត្តមាននៅទីនោះដែរ លោក ម៉ាក ស្វីសូ នាយកអង្គការអាហ្វ្រាកម្ពុជា អភិបាល និងអភិបាលរងស្រុក និងមន្ត្រីមកពីស្ថាប័នពាក់ព័ន្ធ ព្រមទាំងអាជ្ញាធរដែនដី ប្រធាននិងអនុប្រធានការិយាល័យស្រុក ប្រតិបត្តិ ប្រធានមណ្ឌលសុខភាព លោក ឡុង កែវ ប្រធានគម្រោងអង្គការអាហ្វ្រាកម្ពុជា និងសហការី លោក សោម សុវណ្ណនី ប្រធានព្រះវិហារសេវនដែយអាត់វែនទីស្នប្រចាំតំបន់ ព្រមទាំងប្រជាពលរដ្ឋនិងសិស្សានុសិស្សក្នុងឃុំគគីរធំផងដែរ។ នៅក្នុងឱកាសនៃពីធីសម្ពោធនេះ លោក ឡុង កែវ ប្រធានគម្រោងអង្គការអាហ្វ្រាកម្ពុជា ប្រចាំខេត្តកំពង់ធំ បានឡើង រាយការណ៍ដោយសង្ខេបអំពីដំណើរការនៃការសាងសង់ និងដៃគូសហការនានាដែលបាន ចូលរួមធ្វើឲ្យការសាងសង់អាគារ មណ្ឌលសុខភាពនិងបន្ទប់រង់ចាំសម្រាលនេះប្រកបដោយជោគជ័យ។ លោក ឡុង កែវ ក៏បានឲ្យ ដឹងបន្តទៀតអំពីគម្រោងពីរផ្សេងទៀតរបស់ អង្គការអាហ្វ្រាកម្ពុជាដែលកំពុងប្រតិបត្តិនៅក្នុងខេត្តកំពង់ធំ។ ទីមួយគឺគម្រោងអាហារូបត្ថម្ភ សម្រាប់មាតា និងកុមារអាយុក្រោម២ឆ្នាំ (គម្រោងនំ) ដែលបាននឹងកំពុងអនុវត្ត សកម្មភាពរបស់ខ្លួន នៅលើភូមិគោលដៅចំនួន៤៤ ក្នុងឃុំចំនួន៩ នៃស្រុកបារាយណ៍ និងសន្ទុក។ គម្រោងនេះទទួលបានការឧបត្ថម្ភថវិកាពីធនាគារស្បៀងអាហារកាណាដា (CFGB)និងអង្គការអាហ្វ្រាកាណាដា។ គម្រោងនេះមានរយៈពេល៥០ខែ ដែលបានចាប់ផ្តើមតាំងពីឆ្នាំ២០១៥។ គម្រោងនេះសំដៅលើកកំពស់ស្ថានភាពអាហារូបត្ថម្ភដល់សមាជិកគ្រួសារចំនួន២២០០០នាក់ ជាពិសេសស្ត្រីក្នុងវ័យបន្តពូជនិងកុមារ។ ទីពីរ គឺគម្រោងមត្តេយ្យសិក្សាគំរូសាលាប្រាសាទដែលទទួលការឧបត្ថម្ភពីមជ្ឈមណ្ឌល សិក្សា **Kindercare Learning Center** និងអាហ្វ្រាញ៉ូវហ្សីឡេន។ គម្រោងនេះបានសាងសង់អាគារមត្តេយ្យសិស្សាចំនួន១ខ្នងមាន ១បន្ទប់នៅឆ្នាំ២០១៤។ ក្រោយមកនៅឆ្នាំ ២០១៥ អង្គការអាហ្វ្រា បានសហការ ជាមួយអង្គការ រួមធ្លូដែសាងសង់អាគារសិក្សា១ខ្នងបន្ថែមទៀតមាន៦បន្ទប់ ជំនួសអាគារ ចាស់ដែលបានបាក់ទ្រុឌទ្រោមប្រើការលែងកើត ។ ក្រៅពីនេះគម្រោងនៅបន្តផ្តល់ជំនួយផ្នែកបច្ចេកទេសនិងការបណ្តុះបណ្តាល ដល់គ្រូបង្រៀន និងផ្នែកហេដ្ឋារចនាសម្ព័ន្ធសាលាព្រមទាំងមានការគាំទ្រអប់រំផ្នែកអាហារូបត្ថម្ភនៅក្នុងសហគមន៍នោះដោយមានកិច្ចសហប្រតិបត្តិការជាមួយគម្រោងនំខាងលើ។

នៅក្នុងឱកាសនោះដែរ ឯ.ឧ. សុខ លូ អភិបាលនៃគណៈអភិបាលខេត្តកំពង់ធំបានមានប្រសាសន៍ថ្លែងអំណរគុណ យ៉ាងជ្រាលជ្រៅដល់អង្គការអាហ្វ្រាកម្ពុជានិងម្ចាស់ជំនួយដែលបានប្រមែប្រមូលធនធានដើម្បីសាងសង់មណ្ឌលសុខភាពនេះ ព្រមទាំងបន្ថែមនូវបន្ទប់រង់ចាំសម្រាលមួយផងដែរ។ ឯ.ឧ. សុខ លូ បានអំពាវនាវដល់ការិយាល័យស្រុកប្រតិបត្តិឲ្យធានាបាននូវការផ្តល់សេវាប្រកបដោយគុណភាពនិងស្មើភាពគ្នាដល់សហគមន៍ ហើយឲ្យមានការថែទាំអាគារប្រកបដោយវិជ្ជាជីវៈ។ ទាំងអង្គការ អាហ្វ្រាកម្ពុជា និងលោក រ៉ាល់ វ៉ាត់ មកពីហែពអីនធីណេសិនណល បានបញ្ចេញនូវអារម្មណ៍សប្បាយរីករាយដូចៗគ្នា និងថ្លែងអំណរគុណចំពោះកិច្ចសហប្រតិបត្តិការដ៏ល្អពីអាជ្ញាធរមូលដ្ឋានគ្រប់លំដាប់ថ្នាក់ និងដៃគូពាក់ព័ន្ធនានា សម្រាប់សកម្មភាពដ៏ល្អ នៅក្នុងការអភិវឌ្ឍន៍សហគមន៍ឲ្យបានល្អប្រសើរ ប្រកបដោយការទទួលខុសត្រូវ និងមាននិរន្តភាព។

តំណាងសហគមន៍មួយរូបដែលបានចូលរួមក្នុងពិធីនេះបានសម្តែងនូវអារម្មណ៍ “ ខ្ញុំសប្បាយ និងរំភើបរីករាយខ្លាំងណាស់ដែលមានសេវាសុខាភិបាលដែលមានវត្តមាននៅក្នុងសហគមន៍របស់យើងខ្ញុំ ហើយយើងខ្ញុំសូមថ្លែងអំណរគុណដល់ម្ចាស់ជំនួយ ព្រមទាំងមន្ត្រីពាក់ព័ន្ធទាំងឡាយដែលបង្កើតឲ្យមានមណ្ឌលសុខភាពនេះឡើង ”។